**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**
លេខ: ០៣៦ រ.ទ.ស.ភ

# សេចក្ដីជូនដំណឹង
# ស្ដីពី មហាសន្និបាតភាគហ៊ុនិក លើកទី១៣
# របស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (រ.ទ.ស.ភ) មានកិត្តិយស សូមជម្រាបជូនដំណឹងដល់ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនធម្មតារបស់ រ.ទ.ស.ភ ទាំងអស់មេត្តាជ្រាបថា៖ អនុឡោមតាមសេចក្ដីសម្រេចនៅក្នុងកិច្ចប្រជុំលើកទី១៥ របស់ក្រុមប្រឹក្សាភិបាល អាណត្តិទី៨ នាថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៥ រ.ទ.ស.ភ នឹងរៀបចំមហាសន្និបាតភាគហ៊ុនិកសាមញ្ញលើកទី១៣ **នៅថ្ងៃចន្ទ ៥កើត ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៥** ចាប់ពីម៉ោង ៨:០០នាទីព្រឹក នៅទីស្នាក់ការ រ.ទ.ស.ភ និងតាមរយៈប្រព័ន្ធអនឡាញ (Zoom) ដែលមានរបៀបវារៈដូចខាងក្រោម៖

១. ការចុះវត្តមាន
២. ប្រកាសហេតុ
៣. បទបង្ហាញស្ដីពី៖
   ក. របាយការណ៍លទ្ធផលអាជីវកម្ម ឆ្នាំ២០២៤
   ខ. ទិសដៅអាជីវកម្ម ឆ្នាំ២០២៥
   គ. សំណួរ និងចម្លើយ
៤. កម្មវិធីបោះឆ្នោតតាមប្រព័ន្ធអនឡាញ លើកម្មវត្ថុចំនួន៤ ដូចជា៖
   ក. ការបោះឆ្នោតអនុម័តបែងចែកភាគលាភជូនភាគហ៊ុនិក
   ខ. ការបោះឆ្នោតអនុម័តលាភការរបស់ក្រុមប្រឹក្សាភិបាល
   គ. ការបោះឆ្នោតអនុម័តបន្តអាណត្តិជូនអភិបាលឯករាជ្យ និងអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន
   ឃ. ការបោះឆ្នោតលើការបង្កើនដើមទុនរបស់ រ.ទ.ស.ភ
៥. មតិបញ្ចប់ និងសេចក្ដីថ្លែងអំណរគុណរបស់ប្រធានគណៈអធិបតី

ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនធម្មតារបស់ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដែលមានឈ្មោះនៅក្នុងបញ្ជីឈ្មោះភាគហ៊ុនិក **នាថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៥** (កាលបរិច្ឆេទកំណត់ទុកនៃមហាសន្និបាតភាគហ៊ុនិក លើកទី១៣) ត្រូវបញ្ជាក់ការចូលរួមជាមួយ ធនាគារ អេស៊ីលីដា ភីអិលស៊ី (ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់) នៅរៀងរាល់ថ្ងៃធ្វើការចាប់ពី**ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២៥** ដល់ **ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២៥** ចាប់ពីម៉ោង៨:០០នាទី ដល់ម៉ោង ១៦:៣០នាទី។

* **បញ្ជាក់ ៖**

១. ភាគហ៊ុនិកដែលមានសិទ្ធិចូលរួមក្នុងមហាសន្និបាតភាគហ៊ុនិក គឺជាភាគហ៊ុនិកដែលមានឈ្មោះក្នុងបញ្ជីឈ្មោះផ្លូវការដែលទទួលបានពីបញ្ជីឈ្មោះភាគហ៊ុនិកដែលរៀបចំឡើងនៅ**ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៥**។
២. ភាគហ៊ុនិកដែល**លក់** មូលបត្រកម្មសិទ្ធិ (ភាគហ៊ុន) របស់ខ្លួននៅ**ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៥** (កាលបរិច្ឆេទអិចរាយថ៍ / Ex-Right) គឺ **នៅតែមានសិទ្ធិ**ចូលរួម និងបោះឆ្នោតក្នុងមហាសន្និបាត។
៣. ភាគហ៊ុនិកដែល**ទិញ** មូលបត្រកម្មសិទ្ធិ (ភាគហ៊ុន) របស់ខ្លួននៅ**ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៥** (កាលបរិច្ឆេទអិចរាយថ៍ / Ex-Right) គឺ **មិនមានសិទ្ធិ**ចូលរួម និងបោះឆ្នោតក្នុងមហាសន្និបាតឡើយ។



អគារ៤៥ ផ្លូវ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ: (៨៥៥) ៣១ ៩៣៥ ៨០ ៨០ Email: admin@ppwsa.com.kh

៤. ភាគហ៊ុនិកដែលមានសិទ្ធិចូលរួមមហាសន្និបាតភាគហ៊ុនិកលើកទី១៣ របស់ រ.ទ.ស.ភ ប៉ុន្តែមិនបានធ្វើការបញ្ជាក់ការចូលរួមរបស់ខ្លួនជាមួយ ធនាគារ អេស៊ីលីដា ភីអិលស៊ី តាមការកំណត់ខាងលើនេះ នឹងមិនអនុញ្ញាតឱ្យចូលរួមបោះឆ្នោតក្នុងមហាសន្និបាតភាគហ៊ុនិកលើកទី១៣ របស់ រ.ទ.ស.ភ នោះទេ។

៥. ភាគហ៊ុនិកអាចចូលរួមមហាសន្និបាតនេះ ដោយផ្ទាល់ ឬតាមរយៈអាណត្តិគាហកៈ (អ្នកតំណាង)។ ភាគហ៊ុនិកដែលចូលរួមតាមរយៈអាណត្តិគាហកៈ ត្រូវតែងតាំងអាណត្តិគាហកៈរបស់ខ្លួនតាមទម្រង់ "លិខិតតែងតាំងអាណត្តិគាហកៈ (អ្នកតំណាង)" ដែលផ្តល់ដោយ រ.ទ.ស.ភ ឬ ធនាគារ អេស៊ីលីដា ភីអិលស៊ី ដោយត្រូវផ្តល់លិខិតតែងតាំងអាណត្តិគាហកៈនេះមក រ.ទ.ស.ភ តាមរយៈសារអេឡិចត្រូនិក ir@ppwsa.com.kh យ៉ាងយូរត្រឹម**ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២៥** ដើម្បីចូលរួម និងបោះឆ្នោតនៅក្នុងមហាសន្និបាតភាគហ៊ុនិកលើកទី១៣ របស់ រ.ទ.ស.ភ។

៦. រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ សូមរក្សាសិទ្ធិកែប្រែកម្មវិធី របៀបវារៈ និងទម្រង់អនឡាញនៃមហាសន្និបាតភាគហ៊ុនិកលើកទី១៣ របស់ រ.ទ.ស.ភ ក្នុងករណីមានការចាំបាច់។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងទៅកាន់ធនាគារ អេស៊ីលីដា ភីអិលស៊ី និងរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ តាមអាសយដ្ឋាន និងលេខទំនាក់ទំនងដូចខាងក្រោម៖

- **ធនាគារ អេស៊ីលីដា ភីអិលស៊ី**
  អាសយដ្ឋាន : អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
  - **លោក ហួត សុភី**
    ទូរស័ព្ទ : (៨៥៥) ១៥ ៩០០ ៥៣៨
    អ៊ីម៉ែល : hout.sophy@acledabank.com.kh
  - **លោកស្រី សំរិទ្ធ វណ្ណីបុប្ផារដ្ឋ**
    ទូរស័ព្ទ : (៨៥៥) ៧០ ៥០០ ៣៧៧
    អ៊ីម៉ែល : samreth.vannybopharath@acledabank.com.kh
  - **លោក កែន រិទ្ធពុទ្ធា**
    ទូរស័ព្ទ : (៨៥៥) ១៥ ៨០០ ៦៦៣
    អ៊ីម៉ែល : ken.rithputhea@acleda.com.kh
  - **កញ្ញា ចាន់ ទេពកញ្ញា**
    ទូរស័ព្ទ : (៨៥៥) ១៦ ២៩៥ ៤៣២
    អ៊ីម៉ែល : op.rtp@acledabank.com.kh
- **រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**
  - អាសយដ្ឋាន : អាគារ៤៥ ផ្លូវ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
  - ទូរស័ព្ទ : (៨៥៥) ៣១ ៣២២ ៦៣៤៥
  - អ៊ីម៉ែល : ir@ppwsa.com.kh

ថ្ងៃព្រហ. ១៤រោច ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៥

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**
**អគ្គនាយកនៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**

**ឡុង ណារ៉ូ**

**ចម្លងជូន៖**
- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- និយ័តករមូលបត្រកម្ពុជា
- ប្រធាន និងគ្រប់សមាជិកក្រុមប្រឹក្សាភិបាល រ.ទ.ស.ភ
- មន្ត្រីត្រួតពិនិត្យរដ្ឋអម រ.ទ.ស.ភ

  "មេត្តាជ្រាប"
- ឯកសារ-កាលប្បវត្តិ